ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**
**អគ្គលេខាធិការដ្ឋាន**
លេខ: ២៦ /២០១៥ អ.កបធ.សជណ

# សេចក្តីប្រកាសព័ត៌មាន

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ មានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា **នៅថ្ងៃអង្គារ ទី២៤ ខែមីនា ឆ្នាំ២០១៥** ចាប់ពីម៉ោង ១១:០០ ព្រឹក នៅទីស្តីការក្រុមប្រឹក្សាធម្មនុញ្ញ អគារ "**ស**" នៃវិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម ខណ្ឌចំការមន រាជធានីភ្នំពេញ មានបើកកិច្ចប្រជុំពេញអង្គក្រោមអធិបតីភាពរបស់ឯកឧត្តម **ឯក សំអុល** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យ និង សម្រេចលើ ៖

១-សំណើលេខ ២៦១ រ.ស ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ របស់**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

២-សំណើលេខ ២៦២ រ.ស ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ របស់**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

កិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចជាឯកច្ឆន្ទចេញសេចក្តីសម្រេចលេខ ១៥៣/០០១/២០១៥ កបធ.ច និងលេខ ១៥៤/០០២/២០១៥ កបធ.ច ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥